# រឿង ដីងកោ អំបែងកោ



# រឿង ដឹងគោ អំបែងគោ



មានគ្រួសារ ប្តីប្រពន្ធ និងកូនប្រុសម្នាក់ប្រកបរបរកសិកម្មដើម្បីចិញ្ចឹមជីវិត។ បុរសជាប្តីតែងប្រើរទេះគោជាមធ្យោបាយដឹកជញ្ជូន។







ថ្ងៃមួយ បុរសជាប្តីបានទៅខ្ចីដឹងពីអ្នកជិតខាងម្នាក់ ដើម្បីយកទៅចាំងឈើធ្វើកង់រទេះ។ ពេលកំពុងចាំងឈើ ស្រាប់តែ ដឹងរង្គោះផ្លែខ្ទាតចូលទៅក្នុងបឹង។ បុរសនោះក៏ចុះរាវរកផ្លែដឹង តែរកពុំឃើញសោះ ។





បន្ទាប់មក គាត់បានទៅប្រាប់ម្ចាស់ដឹង ដោយអង្វរសុំសងដឹងថ្មីមួយវិញ។ តែម្ចាស់ដឹងនោះពុំយល់ព្រមដោយនិយាយថា "វាជាដឹងកេររបស់វង្សត្រកូលគាត់" ។



បុរសនោះក៏ត្រឡប់ទៅផ្ទះវិញប្រាប់ប្រពន្ធ និងកូនប្រុស។ ប្រពន្ធទៅជួយអង្វរសុំសងជឹងមួយជាពីរ មួយជាបួន មួយជាដប់ក៏ម្ចាស់ជឹងនោះនៅតែមិនយល់ព្រម ដោយនិយាយតែពាក្យដដែលៗថា លុះត្រាតែបានជឹងដើមពិតប្រាកដ ទើបទទួលយក ។









នៅពេលជជែកគ្នាមិនដាច់ស្រេច កូនប្រុសរបស់បុរសខ្វីជើង ក៏និយាយអង្វរថា ចាំខ្ញុំសងកូនគោញីមួយជំនួសវិញ នៅពេលវាផ្តាច់ដោះប៉ុន្មានខែខាងមុខនេះ។ បុរសម្ចាស់ជើងក៏យល់ព្រម។





បីខែក្រោយមក ទឹកក៏រីងហួតហែង បុរសខ្ចីជីងបានដើរទៅរកឧស ស្រាប់តែប្រទះឃើញផ្លែជីងនោះសៀតកប់ក្នុងឫសដើមរាំង។ គាត់ត្រេកអរណាស់ ក៏យកផ្លែជីងនោះទៅដុសលាង ហើយឱ្យកូនប្រុសយកទៅសងគេវិញ។ បុរសម្ចាស់ជីងទទួលយកដោយខកចិត្ត។



នៅពេលស្រូវទុំ ប្តីប្រពន្ធ និងកូនប្រុស នាំគ្នាដាល់អំបុកចោលក្លិនឈ្ងុយទៅដល់ផ្ទះអ្នកជិតខាង ។ កូនស្រីម្ចាស់ដឹងនឹកចង់ហូបអំបុក ក៏ទៅអង្វរម្តាយឱ្យរកអំបែង ។ ម្តាយក៏ចូលទៅខ្ចីអំបែងពីគ្រួសារបុរសខ្ចីដឹងនោះវិញ ។

ក្រោយពីដាល់អំបុករួចហើយ កូនស្រីក៏រៀបចំទុកដាក់អំបែងនៅក្បែរ ជើងក្រាន។ គាប់ជួន មានឆ្កែប្រខាំគ្នាពារលើអំបែងនោះបែកខ្ទេចអស់។





កូនស្រីនោះភ័យណាស់ក៏ទៅប្រាប់ឪពុកម្ដាយ។ បន្ទាប់មកពួកគេក៏ទៅអង្វរសុំសងអំបែងមួយជាពីរ មួយជាបួន មួយជាដប់ ក៏គ្រួសារកូនប្រុសនោះមិនយល់ព្រមដោយនិយាយដដែលៗថា"វាជាអំបែងកេរម៉ែឪបន្សល់ទុកឱ្យ" ។



ពេលនោះ កូនស្រីក៏ស្រក់ទឹកភ្នែកបណ្ដើរ និយាយបណ្ដើរថា "សូមលោកពូអ្នកមីងមេត្តាអាណិតខ្ញុំផង! ព្រោះអំបែងបែកហើយ



មិនអាចភ្ជាប់បានទេ។ សូមមេត្តាអនុគ្រោះឱ្យគ្រួសារខ្ញុំផង។ នៅពេលលោកពូបាត់ផ្លែជីង គ្រួសារខ្ញុំគួរតែទទួលយកជីងថ្មី។ តែឥឡូវនេះគ្រួសារនាងខ្ញុំជួបនឹងស្ថានភាពដូចលោកពូអ្នកមីងពីមុនដែរ។

ខ្ញុំបានដឹងពីអាកប្បកិរិយាខុសឆ្គងនៃគ្រួសារខ្ញុំ ហើយ ខ្ញុំគិតថាលោកពូអ្នកមីងនឹងទទួលយក ចំពោះការអង្វរកររបស់នាងខ្ញុំ" ។







ឃើញហេតុការណ៍ដូច្នេះ កូនប្រុសក៏ជួយអង្វរឪពុកម្ដាយរបស់ខ្លួនដែរថា "ពុកម៉ែ! ការសងសឹកនាំមកតែការឈឺចាប់ទេ។ សូមពុកម៉ែទទួលយកអំបែងថ្មីនេះទៅ"។ បន្ទាប់មក កូនប្រុសក៏ទទួលយកអំបែងថ្មីពីដៃក្មេងស្រីនោះ" ។





ទឹកចិត្តទន់ភ្លន់របស់ក្មេងទាំងពីរនាក់នេះ បានធ្វើឱ្យឪពុកម្តាយទាំងពីរខាងភ្ញាក់រឭក ហើយថែមទាំងធ្វើឱ្យភ្ញាក់ផ្អើល ឮអស់ទាំងអ្នកស្រុកអ្នកភូមិពីម្នាក់ទៅម្នាក់ទៀត។ ម្យ៉ាងទៀត ទង្វើរបស់ក្មេងៗនេះក៏បានធ្វើឱ្យគ្រួសារទាំងពីរស្រុះស្រួលចិត្តគ្នាហើយទទួលស្គាល់ពីកំហុសរៀងៗខ្លួន ។





ចាប់ពីថ្ងៃនោះមក  ចាស់ៗក្នុងភូមិបានកោតសរសើរដល់ក្មេងប្រុសស្រីទាំងពីរនាក់នោះ ដោយណែនាំកូនចៅរបស់គាត់ឱ្យយកតម្រាប់តាមគំរូដ៏ល្អនេះ ៕

---ចប់---

# រឿង ដឹងកេរ អំបែងកេរ

រៀបរៀងដោយ អង្គការសន្តិស្ម័គ្រចិត្ត (SVA) និង វ៉ែន សុន
គូររូបដោយ លោក សារិទ្ធ ចំរើន
រក្សាសិទ្ធិដោយ អង្គការសន្តិស្ម័គ្រចិត្ត(SVA)
បោះពុម្ពឆ្នាំ២០១៣

*Move forward, hand in hand.*

Shanti Volunteer Association

*Stand with people in need around the world.*